ខុមហ្វ្រែល COMFREL

**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី**
**និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)**

# របាយការណ៍សង្ខេបស្តីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៣ ២០១២



តុលា ២០១២

# មាតិកា


I. **សង្ខេបលទ្ធផលរកឃើញ** ........ 2

១. បញ្ហាសន្តិសុខ៖ ........ 2

៣. ការចុះឈ្មោះបោះឆ្នោត/បញ្ជីឈ្មោះបោះឆ្នោត/ការចែកចាយប័ណ្ណព័ត៌មានអ្នកបោះឆ្នោត និងការចេញលិខិតបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការបោះឆ្នោត ........ 4

៤. ការចុះឈ្មោះបេក្ខជនគណបក្សនយោបាយ និងលទ្ធផល ........ 5

៥. ប្រព័ន្ធផ្សព្វផ្សាយ ........ 6

៦. ការឃោសនាបោះឆ្នោត និងមូលនិធិគណបក្សនយោបាយក្នុងពេលឃោសនាបោះឆ្នោត ........ 7

៧. ថ្ងៃបោះ និងរាប់សន្លឹកឆ្នោត ........ 8

៨.បណ្តឹង ........ 9

៩.ការផ្ទៀងផ្ទាត់លទ្ធផល ........ 10

១០.ការចូលរួមរបស់ប្រជាពលរដ្ឋ ........ 10

II. **ការវាយតម្លៃ ជុំវិញដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី ៣ ២០១២** ........ 12

*"សេរី" ក្នុងការបោះឆ្នោតនៅមានកំរិត* ........ 12

*"យុត្តិធម៌" ក្នុងការបោះឆ្នោតមិនមានការកែលំអរ* ........ 13

III. **ការប្រមើលមើលចំពោះការបោះឆ្នោតនាពេលខាងមុខ** ........ 14

# I. សង្ខេបលទ្ធផលរកឃើញ

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) គឺជាអង្គការក្រៅរដ្ឋាភិបាលដែលអង្កេតទៅលើការបោះឆ្នោតតាំងពីឆ្នាំ ១៩៩៨ មកម្ល៉េះ។ ខុមហ្វ្រែលបានធ្វើការអង្កេតការបោះឆ្នោតជាតិ ១៩៩៨ ២០០៣ និង២០០៨ និងបានធ្វើការសង្កេតការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៣ ឆ្នាំ ២០១២ នេះផងដែរ ។ ខុមហ្វ្រែលក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងនាមអង្គការសង្គមស៊ីវិលឯករាជ្យតាមរយៈការតស៊ូមតិ និងសកម្មភាពអប់រំដ៏ទៃទៀតដើម្បីធ្វើឲ្យមានកំរិតស្តង់ដារខ្ពស់ក្នុងដំណើរការបោះឆ្នោត ។

*សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី ៣ នេះ ខុមហ្វ្រែលបានដាក់អ្នកសង្កេតការណ៍រយៈពេលវែង និងខ្លីប្រមាណ ៥,៨៥២ នាក់ រួមទាំងបុគ្គលិក និងសមាជិក/សមាជិកាអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលរួមមាន Center of indigenous Culture (PP), ក្រុមនិស្សិតមកពីសកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (Rule), VBNK, សមាគមស្រាវជ្រាវ និងលើកកំពស់ច្បាប់ខ្មែរ, អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP), GADC (PP), RUPP, Disable Kong Pisey Kampong Speu, (KID), យុវជនខ្មែរ និងការអភិវឌ្ឍន៍សង្គម (KYSD), អង្គការភូមិខ្ញុំ(MVI), DPA (PP), NPA (PP), សមាគមយុវជនខ្មែរ(KYA), មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព(PDP center), Forum Syd, Vigilance, Action for environment and community, KKKHRU, សមាគមន៍ដើម្បីអភិវឌ្ឍន៍ និងការពារសិទ្ធិមនុស្សនៅកម្ពុជា (ADHOC), សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល(FACT), សាលាភាសាអង់គ្លេស និងកុំព្យូទ័រ, ចំរើនស្ត្រី (Chamreoun Satrey), ក្រុមទ្រទ្រង់ភូមិ, Cesvi International Organization, មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ (CLEC) ។*

បន្ទាប់ពីបញ្ចប់ការបោះឆ្នោតឆ្នាំ ២០១២ នេះដែរ ខុមហ្វ្រែលបានរកឃើញជុំវិញដំណើរការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៣ ដូចខាងក្រោម៖

## ១. បញ្ហាសន្តិសុខ៖

ខុមហ្វ្រែលសង្កេតឃើញតាំងពីការចុះឈ្មោះបោះឆ្នោត និងការពិនិត្យបញ្ជីឈ្មោះបោះឆ្នោត រហូតដល់បញ្ចប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី ៣ មានករណីឃាតកម្មទាក់ទិនសកម្មជនគណបក្សនយោបាយចំនួន ៣ ករណី បើទោះបីជាពុំទាន់មានការសន្និដ្ឋានថា ករណីឃាតកម្មទាំងនេះ បានពាក់ព័ន្ធទៅនឹងឃាតកម្មនយោបាយយ៉ាងណាក៏ដោយ ។

ករណីកើតឡើងនៅខេត្តកោះកុង ឃាតកម្មបាញ់សំលាប់លើ លោក ឈុត វុទ្ធី ប្រធានអង្គការការពារធនធានធម្មជាតិ និងបរិស្ថាន ការបាញ់សំលាប់ទៅលើកុមារី ហេង ចន្ថា អាយុ ១៤ ឆ្នាំ នៅខេត្តក្រចេះ ដោយកងកម្លាំងប្រដាប់អាវុធចំរុះ ការសំរេចឃុំខ្លួនយ៉ាងប្រញាប់ប្រញាល់ទៅលើតំណាងសហគមន៍បឹងកក់ចំនួន ១៥

នាក់ដោយសាលារាជធានីភ្នំពេញ និងសកម្មភាពបាញ់បង្ក្រាបបាតុកម្មចំពោះកម្មការិនីចំនួន ៣ នាក់នៅខេត្តស្វាយរៀង ដែលជាការបង្ក្រាបដោយហិង្សារបស់កងកម្លាំងប្រដាប់អាវុធមកលើបាតុកម្មដោយសន្តិវិធីក្នុងប្រទេសកម្ពុជា។ គណៈកម្មាធិការខុមហ្វ្រែលយល់ឃើញថា ករណីហិង្សានេះអាចជះឥទ្ធិពលទៅលើបរិយាកាសដំណើរការបោះឆ្នោត ដែលធ្វើឲ្យប្រជាពលរដ្ឋមានការភ័យខ្លាចក្នុងការប្រើប្រាស់សេរីភាពបញ្ចេញមតិ និងសេរីភាពប្រមូលផ្តុំនៅពេលឃោសនាបោះឆ្នោត ។

ខុមហ្វ្រែលមានការព្រួយបារម្ភចំពោះការគំរាមកំហែង និងការធ្វើទុក្ខបុកម្នេញទៅលើសកម្មជន និងអ្នកនយោបាយដូចជាករណី ការព្យួរអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រ ចាន់ ចេង មកពីគណបក្សសមរង្ស៊ី ការគំរាមកំហែងដល់អាយុជីវិតមកលើលោក មាស សាផល មកពីគណបក្សសិទ្ធមនុស្ស និងការចាប់ខ្លួនលោក មាស ប៉េង មកពីគណបក្សសមរង្ស៊ីមុន និងក្រោយការបោះឆ្នោត ដែលទាំងនេះអាចឲ្យជះឥទ្ធិពលដល់ការបោះឆ្នោតប្រកបដោយសេរី និងយុត្តិធម៌ ។

## ២. អព្យាក្រឹត្យភាពក្នុងការប្រើប្រាស់ធនធានរបស់រដ្ឋ

ធនធានរបស់រដ្ឋរួមទាំងការរំលោភបំពានទ្រព្យសម្បត្តិ និងធនធានមនុស្សរបស់រដ្ឋ ត្រូវបានយកមកប្រើប្រាស់ក្នុងសកម្មភាពគណបក្សប្រជាជនកម្ពុជា ។

ការសង្កេតចាប់ពីថ្ងៃទី ១ ខែកញ្ញា ឆ្នាំ ២០១១ ដល់ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០១២ ការរំលោភបំពានទ្រព្យសម្បត្តិ និងធនធានមនុស្ស ឬមន្ត្រីរបស់រដ្ឋចំនួនប្រមាណ ៥០០ ករណី បើទោះបីជារយៈពេលក្រោយនេះមានការថយចុះនូវការបង្ហាញតួនាទីរដ្ឋរបស់មន្ត្រីរាជការនៅក្នុងប្រព័ន្ធផ្សព្វផ្សាយនៅកំឡុង ពេលធ្វើសកម្មភាពគណបក្សនយោបាយក៏ដោយមុនការឃោសនាបោះឆ្នោត ។ មាន ២៩ ករណី ដែលធនធានមនុស្សរបស់រដ្ឋបានធ្វើសកម្មភាពឃោសនាបំរើគណបក្សប្រជាជនកម្ពុជា ក្នុងកំឡុងពេលនៃការឃោសនាបោះឆ្នោតផ្លូវការ និងតាមរយៈការសង្កេតដោយផ្ទាល់របស់អ្នកសង្កេតការណ៍ខុមហ្វ្រែលក្នុងកំឡុងពេលឃោសនាបោះឆ្នោតនេះដែរ មាន ៣២ ករណី ដែលមន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ នគរបាល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ មេភូមិ អនុភូមិ និងសមាជិកភូមិចូលរួមក្នុងសកម្មភាពឃោសនាគណបក្សកាន់អំណាច ដែលក្នុងនោះមានខេត្តកោះកុង ព្រះវិហារ ពោធិសាត់ រតនគិរី និងព្រៃវែង ។ ជាពិសេសការសង្កេតឃើញមានការប្រើប្រាស់យានជំនិះដែលមានស្លាកសញ្ញារដ្ឋ ប្រើប្រាស់ជាមធ្យោបាយឃោសនាមាន ៩ ករណី ដែលកើតនៅខេត្តរតនគិរី កំពង់ឆ្នាំង និងកែប ។

ឧទាហរណ៍ៈ នៅថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២ នាយឧត្តមសេនីយ មាស សុភា និងលោក អ៊ុំ ម៉ារ៉ា អភិបាលខេត្តព្រះវិហារ បានធ្វើការដឹកនាំប្រជុំជាមួយសមាជិក/សមាជិកា គណបក្សប្រជាជនកម្ពុជា ខេត្តព្រះវិហារ និងថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០១២ អភិបាលខេត្តកែប ហាស់ សារ៉េត ចូលរួមឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី ៣ នៅខេត្តកែប ។

ខុមហ្វ្រែលបានសិក្សាហើយរកឃើញថា បទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ប្រការ៨.៧ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ ២០១២ ដែលមិនស្របតាមច្បាប់មួយចំនួនដោយបានអនុញ្ញាតសកម្មភាពគណបក្សនយោបាយរបស់មន្ត្រីរដ្ឋ

បន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ ឬស្ថិតក្រៅម៉ោងការងារ ។ មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដី គ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងមន្ត្រីតុលាការអាចចូលរួមក្នុងសកម្មភាពឃោសនាគាំទ្រចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ប៉ុន្តែមិនត្រូវស្លៀកពាក់ឯកសណ្ឋាន ឬ/និងមិនត្រូវមានអាវុធជាប់នឹងខ្លួនឡើយ។ មន្ត្រីរបស់រដ្ឋប្រព្រឹត្តល្មើសនឹងប្រការ ៨.៧នេះត្រូវទទួលទោសដូចមានចែងក្នុងមាត្រា ១៣១ នៃច.ប.ត. (ច្បាប់ស្តីពីការជ្រើសតាំងតំណាងរាស្ត្រ) ។ ប៉ុន្តែប្រការនេះមិនត្រូវបានចែងដូចគ្នាជាមួយនឹងច្បាប់ស្តីពីគណបក្សនយោបាយ (១៩៩៧) និងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងច្បាប់ស្តីពីលក្ខន្តិកៈកងយោធពលខេមរភូមិន្ទ ដែលបានហាមឃាត់មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ នគរបាលជាតិ និងមន្ត្រីតុលាកាអនុវត្តនូវសកម្មភាពគាំទ្រគណបក្សនយោបាយណាមួយឡើយ។

គ.ជ.ប បានបកប្រែអព្យាក្រិត្យភាពជាពីរ និយាម ឬស្តង់ដាពីរ ដែលខុសគ្នារវាងមន្ត្រីរដ្ឋ និងអង្គការក្រៅរដ្ឋាភិបាល ធ្វើសកម្មភាពទាក់ទងទៅនឹងការបោះឆ្នោត និងសកម្មភាពនយោបាយដែលដាក់ចូលទៅក្នុងបទបញ្ជា និងនីតិវិធីរបស់ខ្លួន។ ពេលវេលារបស់អង្គការក្រៅរដ្ឋាភិបាល និងសមាគមក្នុងស្រុកមិនបានលើកលែងក្នុងការធ្វើសកម្មភាពនយោបាយបន្ទាប់ពីបំពេញម៉ោងការងារ ឬក្រៅភារកិច្ច។

## ៣. ការចុះឈ្មោះបោះឆ្នោត/បញ្ជីឈ្មោះបោះឆ្នោត/ការចែកចាយប័ណ្ណព័ត៌មានអ្នកបោះឆ្នោត និងការចេញលិខិតបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការបោះឆ្នោត

ការចុះឈ្មោះបោះឆ្នោតឆ្នាំ ២០១១ សម្រាប់បម្រើឲ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ ២០១២ បានបញ្ចប់ដោយគណៈកម្មាធិការរៀបចំការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ និងស្មៀនមួយចំនួនធំបានខិតខំ និងបំពេញតួនាទីដោយចុះឈ្មោះអ្នកបោះឆ្នោតបានជាង ១៩២% (ចំនួន ៩១៥,១៧៨ រូប) នៃចំនួនប៉ាន់ប្រមាណទុក (៤៧៦,០៣៧រូប) និងការលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសំរាប់ឆ្នាំ ២០១១ គឺ ២៧០,៦០៥ នាក់ ។ ជាសរុបចំនួនឈ្មោះក្នុងបញ្ជីបោះឆ្នោតឆ្នាំ ២០១១ មាន ៩,២០៣,៤៩៣នាក់ ដែលលើសពីចំនួនអ្នកមានសិទ្ធិបោះឆ្នោតសរុប ៤% ។ ខុមហ្វ្រែលបានធ្វើការស្រាវជ្រាវដោយរកឃើញថាប្រមាណ ១៧% ស្មើនឹង ១,៥លាននាក់មិនត្រូវបានរកឃើញឈ្មោះ ឬឈ្មោះទាំងនោះត្រូវបានផ្លាស់ប្តូរទាំងស្រុង ហើយអាចប្រឈមនឹងបញ្ហាក្នុងថ្ងៃបោះឆ្នោត ។ ដោយយល់ឃើញថាចំនួនឈ្មោះក្នុងបញ្ជីបោះឆ្នោតឆ្នាំ ២០១១ មានចំនួនលើសពីចំនួនអ្នកមានសិទ្ធិបោះឆ្នោតសរុប ខុមហ្វ្រែលបានធ្វើការសិក្សាស្រាវជ្រាវទៅលើបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ ២០១១ នៅសង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។ ការសិក្សារកឃើញថា ក្នុងចំណោមឈ្មោះចំនួន ៤,១៧៨នាក់បានរកឃើញឈ្មោះស្ទួនចំនួន ១២៧នាក់ (២៥៦ ឈ្មោះ ស្មើនឹង ៣%នៃ៤,១៧៨នាក់) ដែលក្នុងនោះនៅសង្កាត់បឹងទំពុនមានចំនួនអ្នកបោះឆ្នោតសរុប ៣៣,៤៧៥នាក់ និងមានការិយាល័យចំនួន ៥២ ។

ការសង្កេតឃើញថា ដំណើរការនៃការចែកប័ណ្ណព័ត៌មាននេះមិនបានប្រព្រឹត្តទៅដូចអ្វីដែលភាគីពាក់ព័ន្ធរំពឹងទុកនោះទេ ព្រោះថាអ្នកមានតួនាទីបែងចែក ជាពិសេសអាជ្ញាធរមូលដ្ឋានមានការរើសអើងក្នុងការបែងចែក និងបានប្រើប្រាស់វាសម្រាប់ផលចំណេញនយោបាយវិញ។ បើយោងតាមលទ្ធផលនៃការចែកប័ណ្ណព័ត៌មានជូនអ្នកបោះឆ្នោតឆ្នាំ ២០១២ របស់គ.ជ.ប ចេញនៅថ្ងៃទី ១៩ មិថុនា ឆ្នាំ ២០១២ គឺចែកបានប្រមាណ

៨,០០០,៥៨៨% ស្មើនឹង ៨៦,៩៣% ហើយចំនួននៅសល់ ១,២០២,៩០៥នាក់ ប៉ុន្តែខុមហ្វ្រែលនៅតែមានការព្រួយបារម្ភ ចំពោះអ្នកមិនបានទទួលប័ណ្ណព័ត៌មាននេះអាចយល់ច្រឡំថា ពួកគេមិនអាចបោះឆ្នោតបាន ប្រសិនបើគ្មានប័ណ្ណព័ត៌មាន ។ ចំពោះខេត្តដែលចែកច្រើនជាងគេគឺខេត្តស្វាយរៀង ចំនួន ៩៤,៣៧% និងរាជធានីភ្នំពេញត្រូវបានចែកបានតិចជាងគេចំនួន ៧៣,៥២%។

ការចេញទម្រង់ថ្មីគឺលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឲ្យការបោះឆ្នោត ដែលជំនួសឲ្យទម្រង់ ១០១៨ ចាស់ គឺត្រូវបានមើលឃើញថា មានភាពមិនប្រក្រតីជុំវិញដំណើរការនៃការចេញទម្រង់នេះ បើទោះបីជានីតិវិធីនៃកាចេញទម្រង់ថ្មីហាក់មានភាពតឹងរឹង និងច្បាស់លាស់ជាងមុន ប៉ុន្តែតួអង្គដែលត្រូវបានប្រគល់សិទ្ធិឲ្យចេញទម្រង់នេះគឺជដែល ពោលគឺមេឃុំ ចៅសង្កាត់ ដែលមិនមានការទុកចិត្តពីសំណាក់គណបក្សនយោបាយ និងអង្គការសង្គមស៊ីវិល ដោយមេឃុំ ចៅសង្កាត់ខ្លះមិនអនុញ្ញាតឲ្យអ្នកសង្កេតការណ៍ខុមហ្វ្រែលពិនិត្យគល់បញ្ជីក្នុងការចេញទម្រង់នេះ។ យោងតាមរបាយការណ៍របស់គ.ជ.ប ស្តីពីការប្រើប្រាស់លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឲ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី ៣ ចេញនៅថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១២ លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បំរើឲ្យការបោះឆ្នោតបានចេញប្រមាណ ១,០៩៨,៨៩៣ នៅទូទាំងប្រទេសដែលរួមទាំងការផ្តល់ឲ្យកំឡុងពេលចុះឈ្មោះបោះឆ្នោត និងពេលបោះឆ្នោត។

## ៤. ការចុះឈ្មោះបេក្ខជនគណបក្សនយោបាយ និងលទ្ធផល

ដំណើរការចុះឈ្មោះគណបក្សនយោបាយត្រូវបានសង្កេតឃើញថា មានភាពរលូន បើទោះបីជាគណបក្សនយោបាយមួយចំនួនបានជួបការលំបាកក្នុងការបំពេញលក្ខខណ្ឌក្នុងការចុះបញ្ជីបេក្ខជនគណបក្សនយោបាយ។ ជាសរុបមានគណបក្សចំនួន ១០បានចុះឈ្មោះក្នុងនោះគណបក្សប្រជាជនកម្ពុជាបានដាក់បេក្ខជនបានគ្រប់១,៦៣៣ ឃុំសង្កាត់គណបក្សសមរង្សីបាន១,៦១៥ឃុំសង្កាត់ គណបក្សសិទ្ធិមនុស្សបាន ១,០៧០ឃុំសង្កាត់ គណបក្សហ៊្វុនស៊ិនប៉ិចបាន ១,៤១៣ ឃុំសង្កាត់ គណបក្សនយោបាយនរោត្តមរណឫទ្ធិបាន ១,០២៩ ឃុំសង្កាត់ គណបក្សសញ្ជាតិកម្ពុជាបាន ២២៥ ឃុំសង្កាត់ គណបក្សសម្ព័ន្ធប្រជាធិបតេយ្យបាន ៩ ឃុំសង្កាត់ និងគណបក្សនយោបាយចលនាប្រជាធិបតេយ្យបាន ២ ឃុំសង្កាត់។ គណបក្សនយោបាយទាំង ១០ បានចុះឈ្មោះប្រកួតប្រជែងហើយបានដាក់បេក្ខជន និងបេក្ខនារីចំនួនជាង ១១១,០៥៦នាក់ (ស្ត្រី ២៨,៤៨១នាក់) និងក្នុងចំណោមគណបក្សដែលបានដាក់បេក្ខជនទាំងអស់ លើកលែងគណបក្សប្រជាជនកម្ពុជាបានលើកឡើង និងសង្កេតឃើញថា សុទ្ធតែមានបញ្ហាលំបាកក្នុងការស្វែងរកបេក្ខជនមកឈរឈ្មោះ។

ក្នុងការចុះបញ្ជីបេក្ខជនគណបក្សនយោបាយ គ.ជ.ប បានសម្រេចលុបឈ្មោះបេក្ខជនឈរឈ្មោះបោះឆ្នោតនៃគណបក្សនយោបាយចំនួន ២៥នាក់ ដែលមានអាយុមិនគ្រប់២៥ឆ្នាំ និងបានលុបឈ្មោះចំនួន៣៨នាក់ ដែលមានឈ្មោះក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយលើសពីមួយ។

## ៥. ប្រព័ន្ធផ្សព្វផ្សាយ

ការសង្កេតឃើញថា ប្រព័ន្ធផ្សព្វផ្សាយ (ទូរទស្សន៍និងសារព័ត៌មាន) ឯកជនមួយចំនួនមិនគោរពតាមបទបញ្ញា និងនីតិវិធី គោលការណ៍ដែលចេញដោយ គ.ជ.ប ។ យោងតាមគោលការណ៍របស់ គ.ជ.ប ក្នុងពេលយុទ្ធនាការឃោសនាបោះឆ្នោតប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និងឯកជនត្រូវតែធ្វើការបែងចែកឲ្យបានច្បាស់ក្នុងការផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាពជាផ្លូវការរបស់តំណាងរាជរដ្ឋាភិបាល និងសកម្មភាពឃោសនាបោះឆ្នោតដែលធ្វើឡើងក្នុងនាមគណបក្សនយោបាយ បេក្ខជនឬអ្នកគាំទ្រណាមួយ។ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវផ្តល់ព័ត៌មានឲ្យបានត្រឹមត្រូវ មិនលំអៀង និងដោយការថ្លឹងថ្លែងឲ្យមានតុល្យភាព។ ប្រព័ន្ធផ្សព្វផ្សាយទាំងនោះបានធ្វើការចាក់ផ្សាយបំរើឲ្យ ឬមានភាពលំអៀងទៅរកបេក្ខជន និងគណបក្សនយោបាយមួយៗយ៉ាងខ្លាំង ជាពិសេសទូរទស្សន៍ទាំងអស់បន្តដោយឃោសនាឲ្យតែគណបក្សប្រជាជនកម្ពុជា និងតិះតៀនគណបក្សនយោបាយប្រកួតប្រជែងសំខាន់ៗយ៉ាងចាស់ដៃ។

ការសង្កេតលើប្រព័ន្ធផ្សព្វផ្សាយក្នុងអំឡុងពេលពីថ្ងៃទី ១៦ ខែមករា ដល់ថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០១២ បង្ហាញថា គណបក្សប្រជាជនកម្ពុជាកាន់អំណាច នៅតែទទួលបានការផ្សព្វផ្សាយច្រើនជាងគេ ជាពិសេសតាមរយៈប្រព័ន្ធផ្សព្វផ្សាយទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយរដ្ឋ ខណៈដែលគណបក្សមិនកាន់អំណាចផ្សេងទៀតទទួលបាន ការផ្សព្វផ្សាយភាគច្រើនក្នុងប្រព័ន្ធផ្សព្វផ្សាយវិទ្យុឯករាជ្យ។ ក្នុងរយៈពេលនេះដែរប្រព័ន្ធផ្សព្វផ្សាយទូរទស្សន៍ទាំង៣ ដូចជា ទូរទស្សន៍ជាតិកម្ពុជា (ទទក) ស៊ីធីអិន និងបាយ័នព័ត៌មាននៅតែបន្តផ្សព្វផ្សាយលំអៀងទៅកាន់គណបក្សកាន់អំណាច។

ក្នុងអំឡុងពេលឃោសនាបោះឆ្នោតពីថ្ងៃ១៨ ខែឧសភា ដល់ ០១ មិថុនា ការសង្កេតឃើញថាប្រព័ន្ធផ្សព្វផ្សាយទូរទស្សន៍ជាតិកម្ពុជា(ទទក) ទូរទស្សន៍ស៊ីធីអិន ទូរទស្សន៍បាយ័នព័ត៌មាន គណបក្សប្រជាជនកម្ពុជាត្រូវបានផ្សព្វផ្សាយ ២ម៉ោង ៣នាទី ២៨វិនាទី ក្នុងន័យវិជ្ជមាន ១នាទី ១០វិនាទី គណបក្សសមរង្ស៊ី ១ម៉ោង ២៣នាទី ២៤វិនាទី ក្នុងនោះក្នុងន័យអវិជ្ជមាន ៤នាទី ៤៣វិនាទី (ស៊ីធីអិន និងបាយ័នព័ត៌មាន) គណបក្សសិទ្ធិមនុស្ស ១ម៉ោង ៣៧នាទី ១២វិនាទី ក្នុងន័យអវិជ្ជមាន ១៤នាទី ៨វិនាទី (ស៊ីធីអិន និងបាយ័នព័ត៌មាន) គណបក្សនរោត្តមរណឫទ្ធិ ១ម៉ោង ២៣នាទី ២៤វិនាទី គណបក្សហ៊ុនស៊ិនប៊ិច ១ម៉ោង ២៤នាទី រីឯគណបក្សផ្សេងទៀតទទួលបានការផ្សព្វផ្សាយប្រមាណ ១ម៉ោង ៣នាទីម្នាក់ លើកលែងតែគណបក្សសាធារណរដ្ឋប្រជាធិបតេយ្យតែ ៣៩នាទីប៉ុណ្ណោះ។

ប៉ុន្តែមានការភ្ញាក់ផ្អើល សោកស្តាយ និងព្រួយបារម្ភជាខ្លាំងមួយទៀតគឺនៅក្នុងថ្ងៃបោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយមួយចំនួន ដូចជាវិទ្យុសំបុកឃ្មុំ វិទ្យុសារិកា FM 106.5 ឬកម្មវិធី VOD រួមទាំងវិទ្យុអាស៊ីសេរី (RFA) និងវិទ្យុសម្លេងសហរដ្ឋអាមេរិក (VOA) ត្រូវបានហាមឃាត់ក្នុងការផ្សាយពីព័ត៌មានការបោះឆ្នោត ខណៈពេលដែលប្រព័ន្ធផ្សព្វផ្សាយទូរទស្សន៍រដ្ឋ និងឯកជនមួយចំនួនគាំទ្រគណបក្សប្រជាជនកម្ពុជាបានបន្តការផ្សាយអំពីព័ត៌មានបោះឆ្នោត ហើយលំអៀងទៅគណបក្សប្រជាជនកម្ពុជា។

## ៦. ការឃោសនាបោះឆ្នោត និងមូលនិធិគណបក្សនយោបាយក្នុងពេលឃោសនាបោះឆ្នោត

ក្នុងអំឡុងពេលឃោសនាបោះឆ្នោត ការបំភិតបំភ័យ ភាពមិនប្រក្រតី ការរារាំងសកម្មភាពឃោសនារបស់គណបក្សនយោបាយនានាដែលកើតឡើងទៅលើសកម្មជនគណបក្សនយោបាយ និងប្រជាពលរដ្ឋបើគិតជាចំនួនមធ្យមក្នុងមួយថ្ងៃមានការថយចុះបើប្រៀបធៀបទៅនឹងការបោះឆ្នោតមុនៗ (ឆ្នាំ២០០២ កើតឡើងជាង ១០ករណី ក្នុងមួយថ្ងៃ , ឆ្នាំ២០០៧ កើតឡើងប្រមាណ ៨ ករណីក្នុងមួយថ្ងៃ និងឆ្នាំ២០១២ កើតឡើងប្រមាណ ៦ ករណីក្នុងមួយថ្ងៃ)។

មានសកម្មភាពយុទ្ធនាការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយចំនួន ៣ គឺគណបក្សប្រជាជនកម្ពុជា គណបក្សសមរង្ស៊ី គណបក្សសិទ្ធិមនុស្ស ដែលបានដំណើរការទ្រង់ទ្រាយធំនៅទីប្រជុំជន និងទីក្រុង ដូចជាការហែក្បួន ធ្វើការប្រជុំធំៗ និងការបិទខិតប័ណ្ណ ផ្ទាំងរូបភាពផ្សេងៗ ។ល។ ក្រៅពីគណបក្សទាំង ៣ នេះ ការសង្កេតឃើញមានសកម្មភាពឃោសនានៅតាមមូលដ្ឋានឃុំសង្កាត់របស់គណបក្សនយោបាយដែលបានដាក់បេក្ខភាពឈរឈ្មោះតិចមានទ្រង់ទ្រាយតូចៗ។

សំរាប់សកម្មភាពឃោសនាត្រូវបានសង្កេតឃើញថា គណបក្សនយោបាយមានយុទ្ធសាស្ត្រថ្មីៗ ប្រើប្រាស់ឧបករណ៍បច្ចេកវិជ្ជាថ្មីៗ និងកម្មវិធីកំសាន្តច្រើន ដូចជាគណបក្សប្រជាជនកម្ពុជាបានធ្វើការប្រគំតន្ត្រី កម្មវិធីកំសាន្តដោយប្រើប្រាស់អ្នកសិល្បៈ អ្នកកំប្លែង ជាពិសេសប្រើប្រាស់ក្រុមយុវជនសំរាប់ឃោសនាបោះឆ្នោត។ ចំណែកគណបក្សសមរង្ស៊ី បានប្រើបច្ចេកវិជ្ជាថ្មី ដូចជាការចាក់ឌីវីឌី តាមស្រ្គីន អ៊ិល ស៊ី ឌី ក្នុងការនាំសារនយោបាយរបស់ថ្នាក់ដឹកនាំ ក៏ដូចជាគោលនយោបាយរបស់បក្សខ្លួន។

ការចុះហត្ថលេខារវាងគណបក្សហ្វ៊ុនស៊ិនប៉ិច និងគណបក្សនរោត្តមរណឫទ្ធិលើកិច្ចព្រមព្រៀង បង្រួបបង្រួមគ្នាទៅជាគណបក្សតែមួយនៅវិមានសន្តិភាព កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ កន្លងមក។ ប៉ុន្តែគណបក្សទាំងពីរនៅមិនទាន់មានរូបមន្តច្បាស់លាស់នៅឡើយដែរ ហើយការចុះហត្ថលេខាលើកិច្ចព្រមព្រៀងថ្មីៗនេះហាក់មិនមែនជាជំហរពិតប្រាកដរបស់គណបក្សទាំងពីរនោះឡើយ។

មុនពេលប្រកាសបើកយុទ្ធនាការឃោសនាបោះឆ្នោត ក្រុមអង្គការសង្គមស៊ីវិលស្តីពីហិរញ្ញវត្ថុគណបក្សនយោបាយបានរៀបចំពិធីចុះហត្ថលេខារវាងគណបក្សនយោបាយក្នុងការយល់ព្រមផ្តល់នូវព័ត៌មានចំណូល និងចំណាយក្នុងពេលឃោសនាបោះឆ្នោត។ ពិធីចុះហត្ថលេខានោះមានគណបក្សនយោបាយចំនួន ៤ បានយល់ព្រមចុះហត្ថលេខា ដែលមានដូចជា គណបក្សសមរង្ស៊ី គណបក្សសិទ្ធិមនុស្ស គណបក្សហ្វ៊ុនស៊ិនប៉ិច និងគណបក្សចលនាប្រជាធិបតេយ្យ។

ក្នុងកំឡុងពេលឃោសនានេះដែរ ខុមហ្វ្រែលបានដាក់អ្នកសង្កេតការណ៍ដើម្បីប្រមូលព័ត៌មានពីការចំណាយរបស់គណបក្សនយោបាយ។ ខុមហ្វ្រែលប៉ាន់ប្រមាណឃើញថា ដោយពុំទាន់គិតពីការចំណាយថ្នាក់ជាតិរបស់គណបក្សប្រជាជនកម្ពុជាក្នុងឃុំសង្កាត់នីមួយៗ ចំណាយការឃោសនាបោះឆ្នោតមធ្យមប្រមាណជិត ៩,០០០ដុល្លារសហរដ្ឋអាមេរិក, គណបក្សសមរង្ស៊ីប្រមាណជិត ១,៥០០ ដុល្លារសហរដ្ឋអាមេរិក, គណបក្ស

សិទ្ធិមនុស្សប្រមាណជិត ៣០០ដុល្លារសហរដ្ឋអាមេរិក, គណបក្សនរោត្តមរណឫទ្ធិប្រមាណ ២០០ ដុល្លារសហរដ្ឋអាមេរិក និងគណបក្សហ្វ៊ុនស៊ិនប៉ិចប្រមាណជិត ២០០ ដុល្លារសហរដ្ឋអាមេរិក។

## ៧. ថ្ងៃបោះ និងរាប់សន្លឹកឆ្នោត

នៅថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៣ ឆ្នាំ២០១២ បានប្រព្រឹត្តទៅក្នុងលក្ខណៈរលូន បើទោះបីអ្នកចេញភាគរយទៅបោះឆ្នោតមានចំនួនតិចជាងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី២ ២០០៧។ ការសង្កេតការណ៍របស់ខុមហ្វ្រែលតែងតែធ្វើសេចក្តីរាយការណ៍ពីការមិនយល់ដឹងពីនីតិវិធីនៅក្នុងការិយាល័យបោះឆ្នោតរបស់មន្ត្រីការិយាល័យបោះនិងរាប់សន្លឹកឆ្នោត ជាពិសេសខុមហ្វ្រែលសង្កេតឃើញមានភាពមិនប្រក្រតីកើតឡើងជាច្រើនក្នុងថ្ងៃបោះ និងរាប់សន្លឹកឆ្នោត។ ខុមហ្វ្រែលក៏រកឃើញថា ទឹកខ្មៅសំរាប់ជ្រលក់ម្រាមដៃនៅពេលបោះឆ្នោតហើយអាចត្រូវលាងជ្រះ។

ភាពមិនប្រក្រតី ដែលរួមមានប្រមាណ ៣១២៧ ករណីដែលកើតឡើងនៅការិយាល័យចំនួន ៧៨៩ (១៣%)ក្នុងចំណោម ៥៨១០ ការិយាល័យនៅគ្រប់ខេត្ត/ក្រុងដែលអ្នកសង្កេតការណ៍របស់ខុមហ្វ្រែលបានធ្វើការសង្កេត។ ក្នុងនោះភាគច្រើនកើតឡើងនៅភ្នំពេញ ៣៥,៣១%, ពោធិសាត់ ៨,៣៥%, កណ្តាល ៨,៣១%, តាកែវ ៥,៤៧%, បាត់ដំបង ៥,៣៤%, ព្រៃវែង៥,២៤%, បន្ទាយមានជ័យ ៤,៥៤% និងខេត្តផ្សេងៗទៀតក្រោម៤%។ ភាពមិនប្រក្រតីទាំងនោះ ដែលអ្នកសង្កេតការណ៍បានធ្វើការរាយការណ៍រួមមាន ៖

- សកម្មភាពឃោសនាបោះឆ្នោតរំលោភនីតិវិធី ជាពិសេសនៅថ្ងៃស ចំនួន ២៣ (០,៧៤%)ករណី កើតឡើងនៅខេត្ត បាត់ដំបង កំពង់ឆ្នាំង កណ្តាល ភ្នំពេញ ព្រៃវែង ក្រុងព្រះសីហនុ។
- បរិយាកាសនយោបាយ ដែលគ្មានសុវត្ថិភាពនៅក្នុងភូមិជុំវិញការិយាល័យបោះឆ្នោត ចំនួន៩ករណី (០,២៩%) កើតឡើងនៅខេត្តបន្ទាយមានជ័យ កណ្តាល ព្រះវិហារ ព្រៃវែង។
- ការបញ្ជូនសម្ភារៈបោះឆ្នោតមានការយឺតយ៉ាវ និងការខ្វះសម្ភារៈបោះឆ្នោត ដែលធ្វើឲ្យមានការរាំងស្ទះដល់ការបើកការិយាល័យមាន ៣ ករណី (០,១%) កើតឡើងនៅខេត្តក្រចេះ និងព្រៃវែង។
- មានសកម្មភាពឃោសនាតាមរយៈការចែកអំណោយ ឬឃោសនាដោយចែក/បិទផ្ទាំងរូបភាព ឬខិតប័ណ្ណ ដើម្បីគាំទ្របេក្ខជន ឬគណបក្សនយោបាយ២១ ករណី (០,៦៧%) ដែលកើតឡើងនៅខេត្ត កណ្តាល ភ្នំពេញ កំពង់ធំ កំពង់ស្ពឺ កំពត ព្រៃវែង និងកំពង់ឆ្នាំង។
- មានការបដិសេធមិនឲ្យអ្នកសង្កេតការណ៍ ឬភ្នាក់ងារគណបក្សនយោបាយចូលសង្កេតការណ៍ក្នុងការិយាល័យបោះឆ្នោត មាន ១២ ករណី(០,៣៨%) ដែលកើតឡើងនៅភ្នំពេញ កណ្តាល បាត់ដំបង បន្ទាយមានជ័យ កំពង់ស្ពឺ កោះកុង។
- វត្តមានដោយខុសច្បាប់របស់អាជ្ញាធរមូលដ្ឋាន ជាពិសេសមេភូមិស្ថិតនៅជុំវិញការិយាល័យបោះឆ្នោតដើម្បីតាមឃ្លាំមើលអ្នកបោះឆ្នោតមាន ២០៨ ករណី(៦,៦៥%) កើតឡើងនៅ ភ្នំពេញ កណ្តាល ព្រៃវែង តាកែវ កែប ប៉ៃលិន ឧត្តរមានជ័យ ព្រះសីហនុ រតនគិរី ពោធិសាត់ កោះកុង កំពត បន្ទាយមានជ័យ បាត់ដំបង កំពង់ឆ្នាំង កំពង់ធំ កំពង់ស្ពឺ កំពង់ចាម និងព្រះវិហារ។

- កងកម្លាំងប្រដាប់អាវុធស្លៀកពាក់ឯកសណ្ឋាន ឬមានសកម្មភាពយកអាវុធជាតិផ្ទុះ ឬប្រើពាក្យសម្តីនៅខាងក្នុង ឬនៅបរិវេណខាងក្រៅការិយាល័យបោះឆ្នោត មាន ២០ករណី (០,៦៤%) កើតឡើងនៅភ្នំពេញ បាត់ដំបង កំពត កណ្តាល ព្រៃវែង តាកែវ កែប និងប៉ៃលិន។

- នីតិវិធីនៃការបោះឆ្នោត មិនត្រូវបានគោរពពេញលេញដោយមន្ត្រីការិយាល័យ ដែលនាំមកនូវភាពមិនប្រក្រតីចំនួន ១១៤ ករណី(៣,៤៥%) កើតឡើងនៅស្ទើរតែទូទាំងខេត្ត/រាជធានី។

- មានការបដិសេធអ្នកមានសិទ្ធិបោះឆ្នោតមិនឲ្យបោះឆ្នោត (នៅខាងក្នុងការិយាល័យ) មាន១២៩៨ ករណី (៤១,៥១%) ដោយបញ្ហាផ្សេងៗដូចជា គ្មានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត មានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែគ្មានឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការបោះឆ្នោត ខុសទិន្នន័យ ឈ្មោះត្រូវបានបោះរួចហើយ កើតឡើងនៅទូទាំងខេត្ត/រាជធានី។

- មានអ្នកបោះឆ្នោតបានទៅដល់ការិយាល័យបោះឆ្នោត តែមិនបានបោះឆ្នោត (ខាងក្រៅរិយាល័យបោះឆ្នោត) មាន ១០១៦ករណី (៣២,៤៩%) ដោយសាររកឈ្មោះមិនឃើញ រកការិយាល័យបោះឆ្នោតមិនសរឃើញ គ្មានឈ្មោះក្នុងបញ្ជី ប៉ុន្តែធ្លាប់បានបោះឆ្នោតកន្លងមក។ ករណីនេះកើតឡើងនៅទូទាំងខេត្ត/រាជធានី។

**ភាពមិនប្រក្រតីក្នុងពេលរាប់សន្លឹកឆ្នោត**

នៅពេលរាប់សន្លឹកឆ្នោតគេសង្កេតឃើញថា មន្ត្រីការិយាល័យភាគច្រើនមិនទាន់យល់ពីនីតិវិធីនៃការរាប់សន្លឹកឆ្នោត ដែលបណ្តាលឲ្យមានភាពមិនប្រក្រតីចំនួន ៩០ ករណី ដែលក្នុងនោះដូចជា ការអនុញ្ញាតឲ្យអ្នកគ្មានកិច្ចការចូលក្នុងការិយាល័យពេលប្រកាសបិទ មិនមូលភ្ជិតសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោត មានការរំខានដល់ដំណើរការរាប់សន្លឹកឆ្នោត ពន្យារពេលរាប់សន្លឹកឆ្នោត មិនអនុញ្ញាតឲ្យភ្នាក់ងារគណបក្សនយោបាយាចូលសង្កេតដំណើរការរាប់សន្លឹកឆ្នោត និងបញ្ហាផ្សេងៗទៀត។

## ៨.បណ្តឹង

បណ្តឹងក្នុងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៣នេះ ដែលគិតចាប់តាំងពីបណ្តឹងក្នុងពេលចុះឈ្មោះអ្នកបោះឆ្នោត រហូតដល់ថ្ងៃបោះ និងរាប់សន្លឹកឆ្នោត។ ការបដិសេធបណ្តឹងក្នុងកំឡុងពេលចុះឈ្មោះបោះឆ្នោតមានប្រមាណ ៦៨% ក្នុងចំណោម៦១ បណ្តឹង និងបណ្តឹងក្នុងកំឡុងពេលចុះបញ្ជីបេក្ខជនគណបក្សនយោបាយមានប្រមាណ ២៧% នៃបណ្តឹងសរុប ២៩ ត្រូវបានបដិសេធ រីឯបណ្តឹងក្នុងកំឡុងពេលឃោសនាបោះឆ្នោតដែលចេញដោយ គ.ជ.ប មានប្រមាណ ៩១ បណ្តឹងដែលបានប្តឹងនៅថ្នាក់គណកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត។ ក្នុងចំណោមបណ្តឹងទាំងនេះមាន ២៦បណ្តឹងត្រូវបានប្តឹងបន្តនៅគណៈកម្មការរាជធានីខេត្តរៀបចំការបោះឆ្នោត និង ៤ បណ្តឹងត្រូវបានបន្តទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ចំណែកបណ្តឹងនៅថ្ងៃបោះ និងរាប់សន្លឹកឆ្នោត ការសង្កេតឃើញថា មានបណ្តឹងប្រមាណជាង ១៤២ ករណីដែលកើតនៅថ្នាក់គណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត ប៉ុន្តែបណ្តឹងទាំងនោះត្រូវបានភាគច្រើនត្រូវបានបដិសេធ ក្នុងហេតុផលខ្វះឯកសារ ភស្តុតាង ឬបណ្តឹងមិនគ្រប់លក្ខណៈសម្បិត្តិ ដោយពុំមានការចុះស៊ើបអង្កេត

ឲ្យបានស៊ីជំរៅ រកនូវអ្វីដែលជាកង្វះខាតនោះទេ។ គ.ជ.ប មិនមានតម្លាភាពក្នុងការដោះស្រាយបណ្តឹង ដែលធ្វើឲ្យមានភាពមិនទុកចិត្តពីសំណាក់គណបក្សនយោបាយមួយចំនួន នីតិវិធីក្នុងការដោះស្រាយពាក្យបណ្តឹងពុំបានធ្វើការកែលំអ។ បើទោះបីជា គ.ជ.ប បានជ្រើសរើសការដោះស្រាយបណ្តឹងតាមរយៈការសំរប សំរួល ប៉ុន្តែនីតិវិធីនៃការសំរបសំរួលបណ្តឹងទាំងនោះមិនមានតម្លាភាព។

## ៩.ការផ្ទៀងផ្ទាត់លទ្ធផល

ការផ្ទៀងផ្ទាត់លទ្ធផលរបស់ខុមហ្វ្រែល និង គ.ជ.ប ឃើញថា មានគម្លាតភាគរយខុសគ្នាតិចតួច ឧទាហរណ៍ គម្លាតខុសគ្នានៃអ្នកចេញទៅបោះឆ្នោតតែ ០,៦% ខុមហ្វ្រែលរកឃើញថាមាន ៦៤,៥៣% នៃអ្នកមានឈ្មោះក្នុងបញ្ជីបានចេញទៅបោះឆ្នោត ដោយឡែក គ.ជ.ប រកឃើញ ៦៥,១៣%។

ចំណែកលទ្ធផលនៃគណបក្សនយោបាយនីមួយៗ ខុមហ្វ្រែលរកឃើញគម្លាតភាគរយខុសពីគ.ជ.ប ច្រើនបំផុតប្រមាណ ០,០៧% និងតិចបំផុតប្រមាណ ០,០៣%។ ក្នុងចំណោមគណបក្សនយោបាយទាំង ១០ ដែលបានចុះបញ្ជីក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៣នេះ គណបក្សប្រជាជនកម្ពុជាទទួលបានសម្លេងប្រមាណ ៦១,៧៧% គណបក្សសមរង្ស៊ីទទួលបាន ២០,៨១% គណបក្សសិទ្ធិមនុស្សទទួលបានប្រមាណ ៩,៨៣% គណបក្សហ៊្វុនស៊ិនប៉ិចទទួលបាន ៣,៨៧% គណបក្សនរោត្តមរណឬទ្ធិទទួលបាន ២,៩៧% និងគណបក្សផ្សេងទៀតរួមគ្នាទទួលបាន ០,៧៥%។ ដោយឡែកការគណនាចេញវិញលទ្ធផលបឋមតាមគណបក្សរបស់ គ.ជ.ប វិញ គណបក្សប្រជាជនកម្ពុជាទទួលបាន ៦១,៨០% គណបក្សសមរង្ស៊ីទទួលបាន ២០,៨៤% គណបក្សសិទ្ធិមនុស្សទទួលបាន ៩,៨៨% គណបក្សហ៊្វុនស៊ិនប៉ិចបាន ៣,៧៩% គណបក្សនរោត្តមរណឬទ្ធិបាន ២,៩១% និងគណបក្សផ្សេងទៀតសរុបប្រមាណ ០,៧៨%។

## ១០.ការចូលរួមរបស់ប្រជាពលរដ្ឋ

ចំនួនម្ចាស់ឆ្នោតដែលចុះឈ្មោះបោះឆ្នោតមានការកើនឡើងមួយឆ្នាំទៅមួយឆ្នាំនេះ ក៏ដោយសារតែកើនឡើងនៃប្រជាពលរដ្ឋ ប៉ុន្តែបើសង្កេតមើលទៅលើភាគរយម្ចាស់ឆ្នោតដែលបានចេញទៅបោះឆ្នោត មានការថយចុះពីមួយអាណត្តិទៅមួយអាណត្តិ ការសង្កេតឃើញរបស់ខុមហ្វ្រែលរកឃើញការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់លើកទីមួយ ឆ្នាំ២០០២ ចំនួនអ្នកចេញទៅបោះឆ្នោតមានប្រមាណ ៨៧% និងបានថយចុះដល់ប្រមាណ ៦៧% សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់លើកទី២ ឆ្នាំ២០០៧ ហើយនៅតែថយចុះដល់ប្រមាណ ៦៤% សំរាប់ការបោះឆ្នោតឆ្នាំ២០១២។ នេះគឺជាសញ្ញាដែលគួរឲ្យព្រួយបារម្ភ អំពីកំរិតចូលរួមរបស់ប្រជាពលរដ្ឋមានការថយចុះក្នុងដំណើរការបោះឆ្នោត ឬអាចមកពីម្ចាស់ឆ្នោតជួបឧបសគ្គក្នុងថ្ងៃបោះឆ្នោត។ នៅឯការិយាល័យបោះឆ្នោត ម្ចាស់ឆ្នោតបានយល់ពីការគូសសន្លឹកឆ្នោត ប៉ុន្តែយ៉ាងហោចណាស់មានសន្លឹកឆ្នោតមិនបានការប្រមាណ ២% នៅក្នុងថ្ងៃបោះឆ្នោត។

ខុមហ្វ្រែលរកឃើញថា មាន ៤៩% នៃអ្នកអត់បោះឆ្នោត(អ្នកមានទឹកខ្មៅលើម្រាមដៃ) បានទៅដល់ការិយាល័យបោះឆ្នោត ប៉ុន្តែពួកគេមិនអាចបោះឆ្នោត ដោយសារជួបឧបសគ្គ និងបញ្ហាមួយចំនួនដូចជា ការរក

ឈ្មោះក្នុងបញ្ជីបោះឆ្នោតមិនឃើញ គ្មានប័ណ្ណព័ត៌មាន រកការិយាល័យមិនឃើញ គ្មានឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់ប្រើក្នុងការបោះឆ្នោត និងមានឯកសារគ្រប់គ្រាន់តែខុសទិន្នន័យ ៣៦,៦% អ្នកមិនបានបោះឆ្នោត(អ្នកមិនមានទឹកខ្មៅលើម្រាមដៃ) ចង់ទៅបោះឆ្នោត ជាប់រវល់កិច្ចការផ្ទះ មិនបានទទួលព័ត៌មាន រថយន្តឡើងថ្លៃ មិនបានទទួលប័ណ្ណព័ត៌មានអ្នកបោះឆ្នោតមានគេប្រាប់ថា អត់មានសិទ្ធិបោះឆ្នោត។ ចំណែកឯ ១៤% បានលើកឡើងថា មិនចង់ទៅបោះឆ្នោត ដោយសារខ្ជិល ជាប់រវល់កិច្ចការផ្ទះ ជាប់រវល់រកស៊ី/ការងារបោះឆ្នោតមិនមានសារៈសំខាន់។

**១០.១ ស្ត្រី**

យោងតាមលទ្ធផលចុះបញ្ជីបេក្ខជនគណបក្សនយោបាយរបស់ គ.ជ.ប ចំនួនបេក្ខនារីឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៣ នេះមានការកើនឡើង ១៦% ក្នុងឆ្នាំ២០០២ (សរុបក្នុងចំណោម ៨ គណបក្សនយោបាយ) ទៅ ២១,៣៦% ក្នុងឆ្នាំ២០០៧ (សរុបក្នុងចំណោម ១២គណបក្សនយោបាយ) ទៅ ២៥,៦៤% ក្នុងឆ្នាំ២០១២ (ក្នុងចំណោម ១០ គណបក្សនយោបាយ)។

ចំនួនបេក្ខនារីដែលអាចជាប់ឆ្នោតខាងមុខនឹងមិនអាចទៅដល់គោលដៅអភិវឌ្ឍន៍សហវត្សរ៍របស់កម្ពុជា ២៥% នៃសមាជិកក្រុមប្រឹក្សាឃុំនោះទេ។ បើតាមតួលេខពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្ត្រីដែលឈរលេខរៀងទី១ (គណបក្សនយោបាយទាំង ១០ ) មានចំនួនប្រមាណមិនដល់ ១%។

បើទោះបីជាមិនទាន់ដឹងថា ក្នុងថ្ងៃបោះឆ្នោត ចំនួនស្ត្រីចេញទៅបោះឆ្នោតមានចំនួនប៉ុន្មានភាគរយ ប៉ុន្តែខុមហ្វ្រែលបានសិក្សាស្រាវជ្រាវចំពោះអ្នកដែលមិនបានទៅបោះឆ្នោត ពីមូលហេតុដែលមិនបានទៅបោះឆ្នោត។ ក្នុងនោះការសិក្សាស្រាវជ្រាវ ដែលមានស្ត្រីផ្តល់បទសម្ភាសន៍ប្រមាណ ៥១,១% នៃអ្នកផ្តល់បទសម្ភាសន៍សរុប។ ក្នុងចំណោមស្ត្រីដែលមិនបានទៅបោះឆ្នោតមាន ៥១,២% បានទៅបោះឆ្នោត ប៉ុន្តែបានជួបឧបសគ្គដែលក្នុងនោះភាគច្រើនរកឈ្មោះក្នុងបញ្ជីបោះឆ្នោតមិនឃើញ និងគ្មានឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឲ្យការបោះឆ្នោត។

ក្នុងចំណោមស្ត្រីដែលមិនបានទៅបោះឆ្នោត មាន ៣៧% បានលើកឡើងថា ចង់ទៅបោះឆ្នោត តែមិនបានទៅបោះឆ្នោត ដោយភាគច្រើនមិនបានចុះឈ្មោះបោះឆ្នោត។ មាន ១១,៨% ក្នុងចំណោមស្ត្រីដែលមិនបានទៅបោះឆ្នោត បាននិយាយថា មិនចង់ទៅបោះឆ្នោតដែលភាគច្រើនជាប់រវល់កិច្ចការផ្ទះនិងផ្សេងៗ ។

**១០.២ យុវជន**

យុវជនគឺជាតួអង្គយ៉ាងសំខាន់សម្រាប់ការបោះឆ្នោត ហើយបើតាមតួលេខដែលចេញដោយ គ.ជ.ប មានយុវជនប្រហែល ៥៤% ដែលមានអាយុចាប់ពី ១៨ ទៅ ៣៥ឆ្នាំ។ ទោះបីយ៉ាងណា បន្ទាប់ពីការបោះឆ្នោត ខុមហ្វ្រែលបានធ្វើការស្រាវជ្រាវទៅលើអ្នកមិនមានទឹកខ្មៅនៅម្រាមដៃ ឬអ្នកមិនបានទៅបោះឆ្នោត ដែលក្នុងនោះប្រមាណ ៤៩,១% បានផ្តល់បទសម្ភាសន៍ ក្នុងចំណោម ២,៥៣៦នាក់នៅទូទាំងខេត្ត/រាជធានី។

ការសិក្សាបានឃើញពីមូលហេតុដែលយុវជនមិនបានទៅបោះឆ្នោត ដោយក្នុងនោះក្នុងចំណោមយុវជនដែលមិនបានទៅបោះឆ្នោតមាន ៤៦,២១% បានលើកឡើងថា បានទៅបោះឆ្នោត ប៉ុន្តែជួបឧបសគ្គ ដោយក្នុង

នោះភាគច្រើនរកឈ្មោះក្នុងបញ្ជីបោះឆ្នោតមិនឃើញ និងគ្មានឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់ប្រើក្នុងការបោះឆ្នោត។

ក្នុងចំណោមយុវជនដែលមិនបានទៅបោះឆ្នោតនោះដែរមាន ៤១,៧២% បាននិយាយថា ចង់ទៅប៉ុន្តែមិនបានទៅដោយភាគច្រើនមិនបានទៅចុះឈ្មោះបោះឆ្នោត។

យុវជនប្រមាណ ១២,០៦% ក្នុងចំណោមយុវជនមិនបានទៅបោះឆ្នោត បាននិយាយថាពួកគេមិនចង់ទៅបោះឆ្នោតដោយភាគច្រើននិយាយថាខ្ជិល និងជាប់រវល់រកស៊ី/ការងារ។

## II. ការវាយតម្លៃ ជុំវិញដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី ៣ ឆ្នាំ ២០១២

ការសង្កេតរបស់ខុមហ្វ្រែលបានរកឃើញថា ការប្រព្រឹត្តិ និងការចាត់ចែងដំណើរការបោះឆ្នោត មិនមានអំពើហិង្សា និងភាពមិនប្រក្រតីធ្ងន់ធ្ងររហូតធ្វើឲ្យរាំងស្ទះដល់ដំណើរការបោះឆ្នោត ។

ការចាត់ចែង និងការគ្រប់គ្រងការបោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានធានាភាពសម្ងាត់ការបោះឆ្នោត និងភាពរលូននៅថ្ងៃបោះឆ្នោត ។ ទោះបីយ៉ាងណាក៏ដោយ ការចាត់ចែងនេះ មិនទាន់បានធានាឲ្យការបោះឆ្នោតប្រព្រឹត្តទៅដោយត្រឹមត្រូវ និងយុត្តិធម៌ពេញលេញនៅឡើយ ។ ម្យ៉ាងទៀតការចាត់ចែងនេះក៏បានធ្វើឲ្យប៉ះពាល់ការបាត់បង់សិទ្ធិអ្នកបោះឆ្នោតដោយសារការខ្វះគុណភាពបញ្ជីឈ្មោះបោះឆ្នោត ។ ខុមហ្វ្រែលរកឃើញថា មាន ៤៩% នៃអ្នកអត់បានបោះឆ្នោត (អ្នកមិនមានទឹកខ្មៅលើម្រាមដៃ) បានទៅដល់ការិយាល័យបោះឆ្នោត ប៉ុន្តែពួកគេមិនអាចបោះឆ្នោត ដោយសារជួបឧបសគ្គ និងបញ្ហាមួយចំនួនដូចជា ការរកឈ្មោះក្នុងបញ្ជីបោះឆ្នោតមិនឃើញ គ្មានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត រកការិយាល័យមិនឃើញ គ្មានឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់ប្រើក្នុងការបោះឆ្នោត និងមានឯកសារគ្រប់គ្រាន់តែខុសទិន្នន័យ ។

**ខាងក្រោមគឺជាការវាយតម្លៃរបស់ខុមហ្វ្រែលលើដំណើរការបោះឆ្នោតតាំងពីមុនថ្ងៃបោះឆ្នោត ៖**

***"សេរី" ក្នុងការបោះឆ្នោតនៅមានកំរិត***

ប្រជាពលរដ្ឋមួយចំនួននៅតែមានភាពភ័យខ្លាចក្នុងការបង្ហាញការគាំទ្រដល់បេក្ខជន ឬគណបក្សប្រឆាំង ឬក្នុងការបញ្ចេញមតិតិះទៀន ។ បើប្រៀបធៀបទៅនឹងការបោះឆ្នោតអាណត្តិមុន បរិយាកាសដែលបង្កឲ្យមានភាពភ័យខ្លាចដល់ប្រជាពលរដ្ឋមានការធ្លាក់ចុះ នេះដោយសារតែគ្មានឃាតកម្មទាក់ទិនការបោះឆ្នោត និងការធ្លាក់ចុះនៃអំពើហិង្សាបោះឆ្នោតជាច្រើនធៀបការបោះឆ្នោតមុន ។ ប៉ុន្តែក៏នៅមានប្រជាពលរដ្ឋនៅឃុំសង្កាត់មួយចំនួន នៅតែមានភាពភ័យខ្លាច ដោយសារតែករណីហិង្សាខ្លះ បានជះឥទ្ធិពលទៅលើបរិយាកាសមុនការបោះឆ្នោត ដូចជាករណីបាញ់សម្លាប់លោក ឈុត វុទ្ធី នៅខេត្តកោះកុង ការបាញ់ ហើយធ្វើឲ្យកុមារី ហេង ចន្ថា ស្លាប់នៅខេត្តក្រចេះ ការឃុំខ្លួនតំណាងសហគមន៍បឹងកក់នៅរាជធានីភ្នំពេញ និងសកម្មភាពបាញ់បង្ក្រាបបាតុកម្មចំពោះកម្មការិនីនៅខេត្តស្វាយរៀង។

មានគណបក្សនយោបាយចំនួន ១០ បានចុះឈ្មោះប្រកួតប្រជែង ហើយបានដាក់បេក្ខជន និងបេក្ខនារីចំនួនជាង ១១ម៉ឺននាក់ ដែលគណបក្សបានជួបឧបសគ្គតិចតួច ។ សកម្មជន បេក្ខជន និងបេក្ខនារីគណបក្សនយោបាយផ្សេងៗបានធ្វើសកម្មភាពក្នុងកំឡុងពេលឃោសនាបោះឆ្នោត បើទោះបីជាមានការរារាំងខ្លះ ។

អាជ្ញាធរ និងមន្ត្រីរាជការ នគរបាល កងរាជអាវុធហត្ថ និងកងខេមរភូមិន្ទបានធ្វើសកម្មភាពគាំទ្រគណបក្សកាន់អំណាច និងប្រឆាំងគណបក្សផ្សេងទៀត ហើយបន្តមានវត្តមានមន្ត្រីអាជ្ញាធរមូលដ្ឋានដើម្បីឃ្លាំមើលអ្នកបោះឆ្នោតនៅថ្ងៃបោះឆ្នោតក៏បានបង្កើតបរិយាកាសឲ្យអ្នកបោះឆ្នោតភ័យខ្លាច និងមិនទុកចិត្តលើដំណើរការបោះឆ្នោត ។ ការបញ្ចេញមតិតិះទៀនរបស់គណបក្សប្រឆាំង ឬអ្នកប្រឆាំងទៅលើរដ្ឋាភិបាល និងគណបក្សប្រជាជនកម្ពុជា ត្រូវបានចោទប្រកាន់ដាក់ទោស និងពិន័យដោយអាជ្ញាធររៀបចំការបោះឆ្នោត ឬតុលាការ ។

### *"យុត្តិធម៌" ក្នុងការបោះឆ្នោតមិនមានការកែលំអរ*

ការប្រកួតប្រជែងរវាងគណបក្សនយោបាយមិនមានភាពស្មើគ្នា ដោយសារតែអវត្តមានថ្នាក់ដឹកនាំគណបក្សប្រឆាំងធំលំដាប់ទី១ គឺ លោក សម រង្ស៊ី ក្នុងការគាំទ្រ និងធ្វើសកម្មភាពឃោសនាផ្ទាល់ទៅឲ្យគណបក្សខ្លួន និងគម្លាតយ៉ាងធំនៃការទទួល និងការប្រើប្រាស់ធនធានរវាងគណបក្សកាន់អំណាច និងគណបក្សផ្សេងៗ ។

ការទទួលបានការផ្សព្វផ្សាយសំរាប់ការឃោសនាបោះឆ្នោតតាមគោលការណ៍សមធម៌ និងសិទ្ធិទទួលបានព័ត៌មានបោះឆ្នោតមានការធ្លាក់ចុះបើធៀបទៅនឹងការបោះឆ្នោតអាណត្តិមុន ។

មានការប្រើប្រាស់ធនធានរដ្ឋ ទាំងធនធានមនុស្ស និងសម្ភារៈដើម្បីបំរើសកម្មភាពគណបក្សប្រជាជនកម្ពុជា ហើយក៏ប្រឆាំងគណបក្សផ្សេងដែលប្រព្រឹត្តផ្ទុយនឹងច្បាប់ស្តីពីគណបក្សនយោបាយ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងច្បាប់ស្តីពីលក្ខន្តិកៈកងយោធពលខេមរភូមិន្ទ។ ការចូលរួមរបស់មន្ត្រីរាជការកងកម្លាំងប្រដាប់អាវុធ ក្នុងការគាំទ្រគណបក្សកាន់អំណាចមានការកើនឡើង ដែលធ្វើឲ្យបាត់បរិយាកាសអព្យាក្រិត្យភាព ។

មានការផ្តល់សម្ភារៈ និងថវិកាដល់អ្នកបោះឆ្នោតដោយមន្ត្រីរាជការ អាជ្ញាធរ ដែលមានលក្ខណៈជាប្រព័ន្ធ មុនការឃោសនាបោះឆ្នោត ហើយខុមហ្វ្រែលមានការសោកស្តាយដែលច្បាប់បោះឆ្នោតមិនចាត់ទុកករណីនេះជាបទល្មើសទិញសន្លឹកឆ្នោត ។

ការប្រើប្រាស់មូលនិធិគណបក្សនយោបាយក្នុងការប្រកួតប្រជែងមានគំលាតខុសគ្នាយ៉ាងខ្លាំងរវាងគណបក្សកាន់អំណាច និងគណបក្សមិនកាន់អំណាចក្នុងពេលឃោសនាបោះឆ្នោត។ គណបក្សប្រជាជនកម្ពុជាមានលទ្ធភាពប្រើប្រាស់ថវិកាចំណាយដ៏ច្រើនលើសលប់ ខណៈពេលដែលគណបក្សផ្សេងៗមានលទ្ធភាពតិចតួចដោយសារគ្មានច្បាប់កំណត់ការចំណាយ ។

គ.ជ.ប មិនមានតម្លាភាព ក្នុងការដោះស្រាយបណ្តឹង ដែលធ្វើឲ្យមានភាពមិនទុកចិត្តពីសំណាក់គណបក្សនយោបាយមួយចំនួន ។

សំរាប់ការបោះឆ្នោតនេះរាជរដ្ឋាភិបាល និងគ.ជ.ប មិនមានឆន្ទៈនយោបាយពេញលេញក្នុងការកែលំអនីតិវិធី និងការចាត់ចែងបោះឆ្នោតឲ្យបានសេរី ត្រឹមត្រូវ និងយុត្តិធម៌ តាមស្តង់ដា (និយាម) អន្តរជាតិទេ បើទោះបីមានអនុសាសន៍យ៉ាងច្រើនពីអ្នកពាក់ព័ន្ធក្នុងការកែលំអ ដូចជាអានុសាសន៍របស់បេសកកម្មអ្នកសង្កេតការណ៍អន្តរជាតិរបស់សហភាពអឺរ៉ុបជាដើម ។

ជាការសន្និដ្ឋាន លទ្ធផលនៃការបោះឆ្នោតនេះ នឹងចូលរួមបន្ថែមដើម្បីពង្រឹងប្រជាធិបតេយ្យនៅមូលដ្ឋាន ជាពិសេសអភិបាលកិច្ចមូលដ្ឋាន ដោយមានការចូលរួមពីសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ចេញពីគណបក្សផ្សេងៗនៅជាង ៩០% នៃឃុំសង្កាត់ទូទាំងប្រទេស ហើយក៏មានការកើនឡើងចំនួនមេឃុំស្ត្រី និងសមាជិកាក្រុមប្រឹក្សាកើនជាងមុនតិចតួច ។

សំរាប់ការបោះឆ្នោតខាងមុខ ខុមហ្វ្រែលស្នើយ៉ាងទទូច និងជាបន្ទាន់ដល់រាជរដ្ឋាភិបាល គណបក្សនយោបាយ ម្ចាស់ជំនួយ និងអង្គការសង្គមស៊ីវិលដោយត្រូវចាប់ផ្តើមពិភាក្សាកែលំអ រចនាសម្ព័ន្ធ សមាសភាព គ.ជ.ប នីតិវិធី និងយន្តការណសំខាន់ៗមួយចំនួនដូចជាការចុះឈ្មោះបោះឆ្នោត និងការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះបោះឆ្នោត ការដោះស្រាយបណ្តឹងបោះឆ្នោត ការការពារសេរីភាពបញ្ចេញមតិ សេរីភាពខាងព័ត៌មាន ការទទួលបានការផ្សព្វផ្សាយសំរាប់គណបក្សនយោបាយ និងការបង្កើតបរិយាកាសអព្យាក្រិត្យដោយមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធក្នុងន័យពង្រឹងភាពត្រឹមត្រូវ សុច្ចរិតភាព និងយុត្តិធម៌ក្នុងដំណើរការបោះឆ្នោត ។

## III. **ការប្រមើលមើលចំពោះការបោះឆ្នោតនាពេលខាងមុខ**

ការប្រកួតប្រជែងសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៣ គឺហាក់ដូចជាកាន់តែខ្លាំងឡើងៗ។ គណបក្សសិទ្ធិមនុស្ស និងគណបក្សសមរង្ស៊ី បានរួមបញ្ចូលគ្នាជាគណបក្សថ្មីមួយ ដែលមានឈ្មោះថា " គណបក្សសង្គ្រោះជាតិ ឬ CNRP" ហើយគណបក្សថ្មីនេះក៏បានចុះឈ្មោះ និងទទួលស្គាល់ដោយក្រសួងមហាផ្ទៃ ។ ច្បាប់ស្តីពីគណបក្សនយោបាយបច្ចុប្បន្នបានបង្កភាពលំបាកដល់គណបក្សថ្មីរួមបញ្ចូលគ្នានេះ ។ នៅក្នុងករណីដែលការរួមបញ្ចូលគ្នាជាគណបក្សថ្មីមួយ រំលាយគណបក្សទាំងពីរ នោះចំនួនអាសនៈ របស់គណបក្សសិទ្ធិមនុស្ស និងគណបក្សសមរង្ស៊ី នឹងត្រូវបាត់បង់សភា មន្ត្រីជាប់ឆ្នោតជាច្រើនទៀតនៅថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាឃុំសង្កាត់ ។ គណបក្សថ្មីនេះនឹងដឹកនាំដោយប្រធានគណបក្សសមរង្ស៊ីបច្ចុប្បន្ននេះ ដែលត្រូវធ្វើជាប្រធានគណបក្ស ហើយលោក កឹម សុខា ដែលបច្ចុប្បន្នជាអ្នកដឹកនាំគណបក្សសិទ្ធិមនុស្ស ជាអនុប្រធាន។

ទោះបីជាយ៉ាងណា រចនាសម្ព័ន្ធថ្នាក់ក្រោមរបស់គណបក្សថ្មីនេះមិនទាន់ត្រូវបានបង្ហាញ ។ លើសពីនេះភាពមិនច្បាស់លាស់នឹងនៅតែមាន ប្រសិនបើការចោទប្រកាន់ប្រធានគណបក្សសម រង្ស៊ី នឹងមិនត្រូវបានដោះស្រាយរហូតដល់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣។ លោក សម រង្ស៊ីត្រូវបានកាត់ឲ្យជាប់ទោសនៅក្រៅឃុំ រយៈពេល១០ឆ្នាំ ស្តីពីបទ *ការបំផ្លាញទ្រព្យសម្បត្តិសាធារណៈ ការញុះញង់* និង *ការក្លែងបន្លំឯកសារ*។ នៅក្នុងកិច្ចប្រជុំជាន់ខ្ពស់រដ្ឋាភិបាលរវាងរដ្ឋលេខាធិការសហរដ្ឋអាមេរិក គឺលោកស្រី *ហ៊ីល រ៉ូហាម ឡារីគ្លីនតុន (US Department of State Secretary Hillary Rodham Clinton)* ជាមួយ រដ្ឋមន្ត្រីការបរទេសប្រទេសកម្ពុជា គឺលោក *ហោ ណាំហុង (Cambodia Foreign Minister)* ដោយនៅក្នុងនោះលោកស្រី

*គ្នីនតុន* *បានលើកឡើងពីបញ្ហានៃការចូលរួមដោយមានភាពសមស្របមួយចំពោះមជ្ឈដ្ឋាននយោបាយ (Political Spectrum)* សម្រាប់ឆ្នាំ២០១៣ ជុំវិញការកាត់ទោសលោកសម រង្ស៊ី ជាដើម។ ករណីនេះក៏បានទាក់ទាញការចាប់អារម្មណ៍ពីអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមនុស្ស នៃអង្គការសហប្រជាជាតិ លោក ស៊ូរីយ៉ា ស៊ូបេឌី (Surya P. Subedi) ដែលបានសរសេរនៅក្នុងរបាយការណ៍របស់លោកកាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ ២០១២ ស្តីពីស្ថានភាពសិទ្ធិមនុស្ស ដូចជាករណីលោក សម រង្ស៊ី ដែលបានស្នើសុំឲ្យមានការដោះស្រាយផ្នែកនយោបាយ ដើម្បីអាចឲ្យលោកចូលរួមនៅក្នុងការបោះឆ្នោតនាពេលខាងមុខនេះបាន។ រាជរដ្ឋាភិបាលកម្ពុជាអាចនឹងធ្វើការសម្រុះសម្រួលឲ្យមានដំណោះស្រាយពីបញ្ហានេះ ខណៈពេលដែលនឹងមានការប្រជុំកំពូលអាស៊ានបូក (ASEAN Plus including 7th East Asia Summit and Forums) ជាមួយអ្នកដឹកនាំពីបណ្តាបស្ទឹមប្រទេសនានា រួមបញ្ចូលទាំងប្រធានាធិបតីសហរដ្ឋអាមេរិក នៅពាក់កណ្តាលខែវិច្ឆិកា ឆ្នាំ២០១២នេះ។ នេះជាមូលហេតុមួយដែលរដ្ឋាភិបាលអាចកាត់បន្ថយនូវសំពាធពីសហគមន៍អន្តរជាតិ រដ្ឋាភិបាលគួរឲ្យលោក សម រង្ស៊ី ចូលរួមក្នុងការប្រកួតប្រជែងបោះឆ្នោតជ្រើសតាំងអ្នកតំណាងរាស្ត្រខាងមុខ។

គណបក្សផ្សេងទៀតដែលរួមបញ្ចូលគ្នាសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣ នេះត្រូវបានគេប្រកាសឲ្យដឹងដោយគណបក្សនរោត្តមរណឫទ្ធិ និងគណបក្សហ៊្វុនស៊ិនប៉ិច។ ទាំងនេះអាចនឹងបង្កើនឲ្យមានការប្រកួតប្រជែងកាន់តែខ្លាំង និងប្រឈមជាមួយគណបក្សប្រជាជនកម្ពុជា ដូចទៅនឹងគណបក្សប្រឆាំងបច្ចុប្បន្ន ដែលគណបក្សប្រជាជនកម្ពុជាអាចនឹងបាត់បង់សន្លឹកឆ្នោតទៅលើគណបក្សថ្មីនេះ ។ បើទោះជាមានការប៉ុនប៉ងរួមបញ្ចូលនូវគណបក្សទាំងពីរនេះ មុនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ក៏ដោយ ប៉ុន្តែការរួមបញ្ចូលគ្នានេះត្រូវបានបរាជ័យដោយសារតែមានជម្លោះរវាង**សម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ** ដែលជាប្រធានគណបក្សនរោត្តមរណឫទ្ធិ និងឯកឧត្តម **ញឹក ប៊ុនឆៃ** ជាប្រធានគណបក្សហ៊្វុនស៊ិនប៉ិច។ ទោះជាយ៉ាងណានៅក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់មក អគ្គលេខាធិការគណបក្សនរោត្តមរណឫទ្ធិ បានជម្រុញឲ្យមានការរួមបញ្ចូលគ្នានេះដោយជោគជ័យ ជាមួយនិងគណបក្ស ហ៊្វុនស៊ិនប៉ិច ខណៈពេលដែលគណបក្សនរោត្តមរណឫទ្ធិ បានប្តូរឈ្មោះទៅជា "*គណបក្សជាតិនិយម ឬ NP*" វិញ ព្រមទាំងបានប្តូរប្រធានគណបក្សទៀតផង ។ ម្យ៉ាងវិញទៀតសម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ ក៏ធ្លាប់ត្រូវបានស្នើសុំដោយថ្នាក់ដឹកនាំគណបក្សជាតិនិយមដើម្បីឈប់ចូលរួមក្នុងកិច្ចការនយោបាយ និងគណបក្សនយោបាយ ក្នុងនោះសម្តេចក្រុមព្រះបានប្រកាសពីការលាឈប់ពីសកម្មភាពនយោបាយ ។ សម្តេចក្រុមព្រះក៏ត្រូវបានចោទប្រកាន់ដោយគណបក្សហ៊្វុនស៊ិនប៉ិច ថាព្រះអង្គមានគំរោងចូលរួមជាមួយគណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្សក្នុងការផ្លាស់ប្តូរ រដ្ឋាភិបាល និងជំលោះក្នុងការដឹកនាំគណបក្សថ្មីនេះ ។ គណបក្សហ៊្វុនស៊ិនប៉ិច គឺចងសម្ព័ន្ធភាពជាមួយគណបក្សប្រជាជនកម្ពុជា ដោយសារតែមិនមានគោលដៅក្នុងការផ្លាស់ប្តូររដ្ឋាភិបាល ក៏ប៉ុន្តែពួកគេចង់បង្កើនសម្ព័ន្ធភាពនាពេលអនាគត។ ការរួមបញ្ចូលគ្នានៃគណបក្សថ្មីនេះ គឺបន្ទាប់ពីមានការលាលែងរបស់ សម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ ។

យ៉ាងណាមិញ លទ្ធផលនៃការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់នឹងជះឥទ្ធិពលដល់លទ្ធផលនៃការបោះឆ្នោជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៥ ឆ្នាំ២០១៣។ យោងតាមលទ្ធផលនៃការបោះឆ្នោតឃុំសង្កាត់អាណត្តិ

ទី ៣ កន្លងមក លទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ២០១៣ អាចមិនមានការផ្លាស់ប្តូរចំពោះគណបក្សផ្សេងៗទៀតក្រៅពីគណបក្សប្រជាជនកម្ពុជានោះទេ ។ ក្នុងករណីដែលគណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្សបានរួមបញ្ចូលគ្នាប្រកបដោយជោគជ័យ គណបក្សទាំងពីរនេះអាចទទួលបានសម្លេងឆ្នោត ៣០ភាគរយ នៃសន្លឹកឆ្នោត ហើយអាចកើនឡើងចំនួនអាសនៈរហូតដល់៣៦ (ឆ្នាំ២០០៨ ទទួលបានអាសនៈ២៩) ដែលបច្ចុប្បន្ននេះគណបក្ស សមរង្ស៊ី បានកាន់កាប់អាសនៈចំនួន២៦ ជាមួយនឹង ២២ភាគរយនៃសន្លឹកឆ្នោតសរុប ។ ដូច្នេះហើយទើបគណបក្សសិទ្ធិមនុស្ស បានកើនឡើងនូវសម្លេងឆ្នោតសរុប នៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី ៣ ដល់ទៅ១០ភាគរយ បើប្រៀបធៀបជាមួយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០០៨ គណបក្សសិទ្ធិមនុស្ស កាន់កាប់ចំនួន ៣ អាសនៈ បានតែ ៦ ភាគរយ។ ទោះបីជាយ៉ាងណា គណបក្សប្រជាជនកម្ពុជា អាចរក្សាសន្លឹកឆ្នោតដដែល ប៉ុន្តែអាចនឹងបាត់បង់អាសនៈខ្លះទៅគណបក្សដ៏ទៃសំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ ២០១៣ ដែលក្នុងនោះគណបក្សប្រជាជនកម្ពុជាអាចនឹងទទួលបានត្រឹម ៨៦អាសនៈ ជំនួសឲ្យ ៩០អាសនៈដែលបានឈ្នះនៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ២០០៨ ។

លើសពីនេះ ក្នុងករណីដែលគណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សបរាជ័យក្នុងការរួបរួមគ្នា នោះគណបក្សគណបក្សសម រង្ស៊ី អាចនឹងបាត់បង់អាសនៈសភា ទៅឲ្យគណបក្សសិទ្ធិមនុស្ស និងគណបក្សប្រជាជនកម្ពុជា ខណៈពេលដែលគណបក្សសិទ្ធិមនុស្សអាចកើនឡើងនូវសម្លេងឆ្នោត ប្រហែលជា៤ភាគរយ បើប្រៀបធៀបទៅនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៨ ផងដែរ។ លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់បានបង្ហាញថា គណបក្សសមរង្ស៊ី បានបាត់បង់សម្លេងឆ្នោត ។ ចំនួនអាសនៈរបស់គណបក្សសមរង្ស៊ី នឹងមានការថយចុះទៅអោយគណបក្សសិទ្ធិមនុស្ស និងគណបក្សប្រជាជនកម្ពុជាដែលអាចនឹងទទួលបាន២អាសនៈបន្ថែមទៀត ក្នុងគណបក្សនីមួយៗទៅលើអាសនៈដែលមាននៅក្នុងរដ្ឋសភាបច្ចុប្បន្ន។

មានការរំពឹងណាមួយថាគណបក្សជាតិនិយម និង/ឬគណបក្សហ៊្វុនស៊ិនប៉ិចទទួលបានអាសនៈ បើយោងតាមលទ្ធផលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលគណបក្សទាំងពីរនេះអាចរក្សាបានតែចំនួនអាសនៈ២ នៃចំនួនអាសនៈសរុបបច្ចុប្បន្នចំនួន៤អាសនៈបច្ចុប្បន្ននៅក្នុងសភា ។ សម្លេងឆ្នោតរបស់គណបក្សទាំងពីរនេះបានថយចុះគួរឲ្យកត់សំគាល់ នៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់។ ទោះបីជាយ៉ាងណា ការស្មានទុកនៃលទ្ធផលការបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នោត ២០១៣ មិនទាន់អាចដឹងពិតប្រាកដនៅឡើយទេ ដែលអ្នកចេញទៅបោះឆ្នោតអាចមានភាពខុសគ្នាកំឡុងពេលបោះឆ្នោតសភាតំណាងរាស្ត្រ។ ប្រហែលការចាប់អារម្មណ៍របស់អ្នកបោះឆ្នោតបោះឆ្នោតឲ្យគណបក្សនយោបាយនៅក្នុងការដឹកនាំក្រុមប្រឹក្សាឃុំ សង្កាត់ខុសពីការបោះឆ្នោតជ្រើសរើសគណបក្សជាអ្នកតំណាងរាស្ត្រ។

លទ្ធផលការបោះឆ្នោតសម្រាប់ការបោះឆ្នោតព្រឹទ្ធសភាអាណត្តិក្រោយ និងការបោះឆ្នោតក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ(ក្រុមប្រឹក្សាខេត្ត/ស្រុក)អាចត្រូវបានគណនាចេញពីសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ និងសមាជិក

សភាតំណាងឲ្យប្រជាពលរដ្ឋដែលជាអង្គបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា។ វិន័យរបស់គណបក្សនយោបាយគឺមានភាពតឹងរឹងសំរាប់គណបក្សនយោបាយក្នុងប្រទេសកម្ពុជា ហើយវាអាចត្រូវបានគេរំពឹងទុកថាអង្គបោះឆ្នោតនឹងត្រូវបានធ្វើឡើងតាមបញ្ជារបស់គណបក្ស ។ ព្រោះបេក្ខជនឯករាជ្យ គឺមិនត្រូវបានឲ្យអនុញ្ញាតនៅក្នុងការបោះឆ្នោតនេះទេ។ ហេតុដូច្នេះហើយ ពឹងផ្អែកទៅលើលទ្ធផលបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ ២០១២ និងសន្មត់ថាគណបក្សប្រជាជនកម្ពុជា អាចកាន់កាប់អាសនៈនៅក្នុងសភារបស់ខ្លួន សម្រាប់ឆ្នាំ ២០១៣ មានចំនួនថយចុះ ២អាសនៈ ដែលក្នុងនោះថយពី ៤៦អាសនៈ មក ៤៤អាសនៈ ឬថយមកត្រឹម ៨០ ភាគរយ (បច្ចុប្បន្នគណបក្សប្រជាជនកម្ពុជាកាន់កាប់ច្រើនជាង ៨០%ឬ៤៦អាសនៈ នៃចំនួនអាសនៈព្រឹទ្ធសភាសរុប៥៧អាសនៈ) ដែលនៅក្រោមការត្រួតត្រា និងបន្តកាន់កាប់ដោយប្រព័ន្ធគណបក្សកាន់អំណាចតែមួយ ។ គណបក្សសមរង្ស៊ី និង/ឬគណបក្សសិទ្ធិមនុស្សអាចនឹងទទួលបានចំនួនអាសនៈក្នុងព្រឹទ្ធសភាដែលកើនឡើងចំនួន ២អាសនៈ កើនពី ១១អាសនៈ ទៅ ១៣អាសនៈ (បច្ចុប្បន្ន គណបក្សសមរង្ស៊ី និង/ឬគណបក្សសិទ្ធិមនុស្សកាន់កាន់ប្រមាណ ១៩% នៃចំនួនអាសនៈព្រឹទ្ធសភាសរុប ៥៧អាសនៈ)។ ដូចគ្នាដែរ ការបោះឆ្នោតអសកល ជ្រើសរើសក្រុមប្រឹក្សាខេត្ត និងស្រុក គណបក្សប្រជាជនកម្ពុជានឹងអាចទទួលបាន ៧៩ភាគរយ នៃអាសនៈថ្នាក់ក្រោមជាតិ ខណៈពេលដែលគណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្ស នឹងអាចទទួលបាន២១ភាគរយនៃអាសនៈក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ។ គណបក្សជាតិនិយម ឬ និងគណបក្សហ្វ៊ុនស៊ិនប៉ិចនឹងទទួលបានតិចជាង១ភាគរយនៃចំនួនអាសនៈ ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។ ចំនួនអាសនៈសរុបសំរាប់អាសនៈក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ រួមបញ្ចូលទាំងក្រុមប្រឹក្សាស្រុក/ខណ្ឌ រាជធានី/ខេត្តគឺច្រើនជាង ៣,០០០អាសនៈ ។

ជាសរុបដោយផ្អែកលើលទ្ធផលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់នាពេលថ្មីៗនេះ ត្រូវបានបង្ហាញពីការថយចុះតិចតួចរបស់គណបក្សប្រជាជនកម្ពុជាសំរាប់អាសនៈព្រឹទ្ធសភា ក្រុមប្រឹក្សាខេត្ត/ស្រុក/រាជធានី និងសមាជិកសភា រីឯគណបក្សសង្គ្រោះជាតិ (CNRP) ឬគណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្ស (ក្នុងករណីការរួបរួមគ្នាបានជោគជ័យមុនការបោះឆ្នោត) នឹងមានការកើនឡើងតិចតួចចំនួនសមាជិកសភា និងក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ។ គណបក្សហ្វ៊ុនស៊ិនប៉ិច និង/ឬគណបក្សជាតិនិយម ផ្ទុយទៅវិញអាចនឹងបាត់បង់អាសនៈដ៏ច្រើនរបស់ខ្លួនសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៥។

# ឧបត្ថម្ភដោយ

សេចក្តីអធិប្បាយនៅក្នុងរបាយការណ៍នេះ ជាការទទួលខុសត្រូវទាំងស្រុងរបស់អង្គការខុមហ្វ្រែល ហើយមិនអាចយកទៅប្រើប្រាស់ក្នុងរូបភាពណាមួយ ដើម្បីឆ្លុះបញ្ចាំងពីទស្សនៈរបស់ម្ចាស់ជំនួយឡើយ ។


ខុមហ្វ្រែល COMFREL

**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា**

ផ្ទះលេខ ១៣៨ ផ្លូវ ១២២ ទឹកល្អក់១ ទួលគោក ភ្នំពេញ ប្រអប់សំបុត្រលេខ ១១៤៥

ទូរស័ព្ទ ០២៣ ៨៨៤ ១៥០ ទូរសារ ០២៣ ៨៨៥ ៧៤៥

អ៊ីម៉ែល: comfrel@comfrel.org, comfrel@online.com.kh

គេហទំព័រ: www.comfrel.org